# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់**

**និងប្រព័ន្ធយុត្តិធម៌**

**អគ្គលេខាធិការដ្ឋាន**

## កំណត់ហេតុ សិក្ខាសាលាស្តីពីលទ្ធផលនៃការស្ទង់មតិជាមូលដ្ឋានលើសមត្ថភាព តាក់តែងច្បាប់របស់អង្គភាពនីតិកម្មនៃក្រសួងឬស្ថាប័ន  នៅសណ្ឋាគារណាហ្គាវើល

ឆ្នាំពីរពាន់ប្រាំបួន ខែតុលា ថ្ងៃទីម្ភៃបី វេលាម៉ោងប្រាំបីកន្លះព្រឹក នៅសាលប្រជុំសណ្ឋាគារណាហ្គាវើល រាជធានីភ្នំពេញ មានរៀបចំសិក្ខាសាលាមួយក្រោមអធិបតីភាពរបស់ឯកឧត្តម **ស៊ុយ ម៉ុងលាង** អគ្គលេខាធិការ នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ ដើម្បីពិនិត្យ និងពិភាក្សាកែលំអរបាយការណ៍សិក្ខាសាលាស្តីពី លទ្ធផលនៃការស្ទង់មតិជាមូលដ្ឋានលើសមត្ថភាពតាក់តែងច្បាប់របស់អង្គភាពនីតិកម្មនៃក្រសួង ឬស្ថាប័ន។

សមាសភាពអ្នកចូលរួមប្រជុំមានដូចបញ្ជីជូនភ្ជាប់មកជាមួយ។

ជាកិច្ចចាប់ផ្តើមឯកឧត្តម **ស៊ុយ ម៉ុងលាង** បានសម្តែងនូវកិច្ចស្វាគមន៍ចំពោះអង្គសិក្ខាសាលាទាំងមូល។ ជាបន្ទាប់ឯកឧត្តមប្រធានបានធ្វើបដិសណ្ឋារកិច្ចចំពោះភ្ញៀវកិត្តិយសទាំងអស់រួចមក ឯកឧត្តមប្រធានបានជម្រាបជូនអង្គ សិក្ខាសាលាទាំងមូលថា សិក្ខាសាលាដ៏សំខាន់នាថ្ងៃនោះ គឺជាដំណាក់កាលបន្តពី «សិក្ខាសាលាណែនាំស្តីពី ការស្ទង់មតិជាមូលដ្ឋានលើសមត្ថភាពតាក់តែងច្បាប់របស់អង្គភាពនីតិកម្មនៃក្រសួង ឬស្ថាប័ន» លើកទី១ ដែលបានរៀបចំឡើងកាលពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៨ កន្លងមក។

ការពង្រឹងសមត្ថភាពនៃអង្គភាពនីតិកម្ម របស់ក្រសួងនីមួយៗបិតនៅក្នុងផែនការសកម្មភាព លេខ ២.៣.៤ ដែលតម្រូវឱ្យមានការស្វែងយល់ពីស្ថានភាពបច្ចុប្បន្ន សេចក្តីត្រូវការនិងការផ្គត់ផ្គង់របស់អង្គភាពនីតិកម្មនាជាមុនសិន។ ហេតុនេះ ហើយបានជាយើងចាំបាច់ត្រូវធ្វើការស្ទង់មតិជាមូលដ្ឋានលើអង្គភាពនីតិកម្ម និងសមត្ថភាពតាក់តែងច្បាប់របស់ក្រសួង ឬស្ថាប័នមុននឹងធ្វើផែនការរួមដើម្បីពង្រឹងសមត្ថភាពនៃអង្គភាពនីតិកម្មនៅតាមក្រសួងនានា។ ការស្ទង់មតិមានគោលដៅស្វែងយល់លើបញ្ហាសំខាន់ៗចំនួន៤គឺៈ ១-ស្ថានភាពបច្ចុប្បន្នលើការតាក់តែងច្បាប់ និងស្ថាប័នដែលពាក់ព័ន្ធ

ក្នុងដំណើរការ តាក់តែងច្បាប់ដូចជាក្របខណ្ឌច្បាប់ យន្តការតាក់តែងច្បាប់ គោលការណ៍ណែនាំទាក់ទងនឹងការតាក់តែងច្បាប់ និងធនធាននៃការតាក់តែងច្បាប់ជាដើម ២-សេចក្តីត្រូវការដើម្បីបំពេញសមត្ថភាពនៃការតាក់តែងច្បាប់របស់អង្គភាពនីតិកម្ម ៣-ការផ្តត់ផ្គង់ ដើម្បីបំពេញសមត្ថភាពនៃការតាក់តែងច្បាប់របស់អង្គភាពនីតិកម្ម និង ៤-វិធានការដើម្បីធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពនៃការតាក់តែងច្បាប់របស់អង្គភាពនីតិកម្ម។

លោកស្រី Katharina Hubner, GTZ បានបញ្ចេញទស្សនៈថា ប្រសិនបើចង់ឱ្យកម្ពុជាមានច្បាប់គ្រប់គ្រាន់ ត្រូវមានគោលនយោបាយច្បាស់លាស់ និងចូលទៅក្នុងនិយ័តកម្មដ៏ល្អមួយត្រូវមានសមាសភាពសំខាន់បីគឺ៖

១- ធ្វើយ៉ាងណាឱ្យអ្នកព្រាងច្បាប់មានសមត្ថភាពខ្ពស់ និងឱ្យមានស្តង់ដាអន្តរជាតិ

២- នៅតាមក្រសួង អង្គភាពនីតិកម្មត្រូវមានការទទួលខុសត្រូវដោយតំណាងក្រសួង និងយកចិត្តទុកដាក់ដោយ ថ្នាក់ដឹកនាំរបស់ក្រសួង

៣- ត្រូវឱ្យមានក្របខ័ណ្ឌនិយ័តកម្ម និងមានធនធានមនុស្ស ។

ឯកឧត្តម **សួន លាងហៃ** អគ្គលេខាធិការរង នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ បានធ្វើបទបង្ហាញអំពីប្រវត្តិនៃការធ្វើការស្ទង់មតិ ចាប់ពីការរៀបចំដំបូងរហូតការដល់ចេញជាលទ្ធផលនាថ្ងៃនោះ។

លោក **គង់ ផល្លះ** អនុប្រធានផ្នែកកំណែទម្រង់ច្បាប់ និងឯកឧត្តម **ម៉ែន ម៉ុនឈា** អគ្គលេខាធិការរង នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ បានធ្វើបទបង្ហាញ និងបញ្ជាំងស្លាយ តាមរយៈឯកសារដែលបានចែកជូន អង្គសិក្ខាសាលាទាំងមូល ដែលមានចំណងជើងថា «**ការស្ទង់មតិជាមូលដ្ឋានលើអង្គភាពនីតិកម្ម និងសមត្ថភាពតាក់តែង ច្បាប់របស់ក្រសួង ធ្វើនៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩**» ។ លោក **គង់ ផល្លះ** បានធ្វើការបង្ហាញអំពីលទ្ធផលនៃការស្ទង់ មតិ ចាប់ពីទំព័រទី១៣ ដល់ទំព័រ ៥៥ ចំណែកឯកឧត្តម **ម៉ែន ម៉ុនឈា** បានធ្វើការបង្ហាញអំពីអនុសាសន៍ ចាប់ពីទំព័រទី៥៦-៥៨ នៃសេចក្តីព្រាងរបាយការណ៍។

ឯកឧត្តមប្រធានអង្គសិក្ខាសាលាបានមានប្រសាសន៍ថា តាមការធ្វើបទបង្ហាញយើងឃើញថាមានចំណុចមួយ ដែលចាំបាច់បំផុតគឺថាត្រូវតែមានអង្គភាពនីតិកម្មនៅក្នុងក្រសួងនីមួយៗ ព្រោះអង្គភាពនេះវាមានការពាក់ព័ន្ធទៅនឹងដំណើរការតាក់តែងច្បាប់ក្នុងកម្ពុជា។ ឯកឧត្តមប្រធានបានកត់សំគាល់ថា មិនទាន់មានការសម្រេចអំពីដំណើរការនៃការតាក់តែងច្បាប់នៅឡើយទេ តែអ្វីដែលជាភាពប្រាកដនោះគឺថា ក្រសួង-ស្ថាប័នទាំងអស់មានតួនាទីតាក់តែងច្បាប់ជាទូទៅរួចស្រេចហើយ។ នៅក្នុងសេចក្តីណែនាំ អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល ជាអ្នកចាំទទួលយកលិខិតបទដ្ឋានដែល

ក្រសួង-ស្ថាប័នបានផ្ញើ មកជារៀងរាល់ឆ្នាំមានន័យថា ក្រសួង-ស្ថាប័នជាអ្នកផ្តើមធ្វើសេចក្តីព្រាងរៀងៗខ្លួន។ អំពីច្បាប់ក្រសួង-ស្ថាប័នមាន ឯកសារបី ដែលត្រូវយោងគឺ៖

១- ឯកសារយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល

២- ឯកសារផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ **NSDP** និងកំណែទម្រង់ច្បាប់ និងតុលាការ

៣- ឯកសារអភិបាលកិច្ចទី ៣ (កំពុងតែរៀបចំ) ។

តំណាងអាកាសចរស៊ីវិល បានមានប្រសាសន៍ថា ខាងលោកមានការសោកស្តាយចំពោះក្រុមការងារខាងផ្នែកស្ទង់មតិ ដែលមិនបានចុះទៅស្ទង់មតិនៅអាកាសចរស៊ីវិលនោះ។ លោកបានស្នើសុំផងដែរឱ្យអង្គភាពនីតិកម្មមានភាពឯករាជ្យ និងស្ថិតនៅក្រោមស្ថាប័នតែមួយប៉ុណ្ណោះ។ ចំពោះការបណ្តុះ-បណ្តាលធនធានមនុស្សក៏មានការលំបាក ហើយអ្នកឯកទេសបរទេសក៏មានការខ្វះខាត។

លោក **ឥង់ ឥណ្ឌះ** អនុប្រធានផ្នែកគម្រោងកំណែទម្រង់ច្បាប់ នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌បានសូមអភ័យទោសចំពោះការខ្វះចន្លោះហើយសន្យាថា បើមានការចាំបាច់លោកនឹងចុះទៅអាកាសចរស៊ីវិលដើម្បីប្រមូលព័ត៌បន្ថែម។

ឯកឧត្តមប្រធានអង្គសិក្ខាសាលាមានចម្លល់ផងដែរ ចំពោះការខ្វះខាតក្នុងការចុះស្ទង់មតិនេះ ហើយឯកឧត្តម ប្រធានបានមានប្រសាសន៍ថា គួរតែពង្រឹងដោយខ្លួនយើង លើកលែងតែច្បាប់ធំៗសឹមយើងពឹងអ្នកឯកទេសបរទេសឱ្យ ជួយ។ ឯកឧត្តមប្រធានបានផ្តល់ជាអនុសាសន៍បន្ថែមទៀតថា ៖

- គួរតែមានទំនាក់ទំនងជាមួយក្រុមប្រឹក្សាអ្នកច្បាប់ជាមុនក្នុងការតាក់តែងច្បាប់ ជាពិសេសលើទម្រង់ និងរបៀបសរសេរជាដើម
- ពង្រឹងអង្គភាពនីតិកម្មតាមក្រសួងនីមួយៗឱ្យបានរឹងប៉ឹង
- ដើម្បីកុំឱ្យមានភាពតឹងតែងពេកនៅពេលប្រជុំអន្តរក្រសួង នៅពេលសរសេរសេចក្តីព្រាងខាងក្រសួងសាមី គួរតែទាក់ទង ឬសម្របសម្រួលឱ្យហើយ។

លោកជំទាវ **ចាន់ សុខុន្ធាទី** បានលើកជាអនុសាសន៍ថា ក្នុងការតាក់តែងច្បាប់ពិសេសនៅតាមក្រសួងស្ថាប័ន គួរតែធ្វើយ៉ាងណាឱ្យបានស្របតាមច្បាប់ ជាមូលដ្ឋានដែលអនុម័តរួចហើយ។

លោក **ឥង់ ឥណ្ឌះ** បានឆ្លើយបំភ្លឺថា ពេលដែលចុះទៅសម្ភាសន៍ ភាគច្រើននៃអ្នកសម្ភាសន៍ចង់ចេះតែរបៀបសរសេរតាក់តែងច្បាប់តែប៉ុណ្ណោះ ហើយលើកយកតែច្បាប់ពិសេសដែលក្រសួងរបស់គាត់ត្រូវការ។ ពាក់ព័ន្ធសេចក្តីណែនាំ និងនីតិវិធីនៃការតាក់តែងច្បាប់ខាងក្រសួងស្ថាប័នចង់ឱ្យមានគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល ធ្វើយ៉ាងណាឱ្យស៊ីចង្វាក់គ្នា ដើម្បីកុំឱ្យមានភាពចំរូងចំរាស់គ្នានៅពេលដែលឡើងទៅដល់ក្រុមប្រឹក្សាអ្នកច្បាប់ និងស្នើសុំឱ្យមានស្តង់ដាតែមួយ។

លោក **សុខ ខឿន** ប្រធានការិយាល័យសន្ធិសញ្ញា និងកិច្ចព្រមព្រៀងក្រសួងការបរទេស បានឯកភាពចំពោះ មតិថាត្រូវស្របតាមច្បាប់រដ្ឋធម្មនុញ្ញ និងគោលនយោបាយរបស់រាជរដ្ឋាភិបាល ហើយបានស្នើសុំឱ្យពិនិត្យទៅលើលិខិតបទដ្ឋាន អន្តរជាតិផ្សេងៗ និងអនុសញ្ញាសិទ្ធិសញ្ញាអន្តរជាតិ ជាពិសេសស្ថាប័នពាក់ព័ន្ធ។

ឯកឧត្តម **អ៊ឹង តិរុន** រដ្ឋលេខាធិការក្រសួងសុខាភិបាលស្នើសុំថា នៅពេលដែលច្បាប់ចេញ ហើយសូម ឱ្យមានការផ្សព្វផ្សាយឱ្យបានដល់ប្រជាពលរដ្ឋ និងមន្ត្រីរាជការឱ្យបានយល់ដឹង និងស៊ីជម្រៅ។ ហើយឯកឧត្តមបានជម្រាបថា នៅក្រសួងសុខាភិបាលក្នុងនីតិវិធីតាក់តែងច្បាប់ គឺបានបង្កើត ត្រឹមតែការិយាល័យនីតិកម្មថ្នាក់ក្រសួងប៉ុណ្ណោះ។

តំណាង AusAid បានមានប្រសាសន៍ថា តាមការពិសោធន៍របស់ប្រទេសអូស្ត្រាលី លោកស្រី បានយល់ស្របទៅ លើអនុសាសន៍សំខាន់ៗចំនួន៤ ដែលបានលើកបង្ហាញដោយ ឯកឧត្តម **ប៉ែន ម៉ុនឈា** តាមរយៈការបញ្ចាំងស្លាយ។ ជាមួយគ្នានោះផងដែរ លោកស្រីបានស្នើសុំឱ្យមានការ ពិគ្រោះយោបល់គ្នាឱ្យកាន់តែទូលំទូលាយនៅក្នុងរាជរដ្ឋាភិបាល ដើម្បីឱ្យមានការចូលរួមពីវិស័យ ឯកជន អង្គការក្រៅរដ្ឋាភិបាល មុននឹងដាក់ច្បាប់នោះទៅទីស្តីការគណៈរដ្ឋមន្ត្រី។

តំណាងក្រសួងមហាផ្ទៃ បានឯកភាពទាំងស្រុងទៅលើរបាយការណ៍ដែលបានបង្ហាញ ប៉ុន្តែ លោកបានលើកឡើងត្រង់ចំណុចអនុសាសន៍ស្តីអំពីការបង្កើតអង្គភាពនីតិកម្មត្រឹមថ្នាក់នាយកដ្ឋាន ឬការិយាល័យ ពីព្រោះក្រសួងមហាផ្ទៃបានបង្កើតថ្នាក់ក្រុមប្រឹក្សា។

តំណាងក្រសួងសាធារណៈការ បានជំរុញឱ្យក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ស្វែងរកមូលិធិ ដើម្បីជួយដល់អង្គភាពនីតិកម្មនៅតាមបណ្តាក្រសួង-ស្ថាប័ន និងស្នើសុំឱ្យជួយកែរចនាសម្ព័ន្ធឱ្យបានដូចគ្នាផងដែរ។

លោក **រស់ ដារ៉ុឆ** តំណាងក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ បានស្នើសុំឱ្យមានការបន្ថែម លើប្រាក់លាភការ សម្រាប់ក្រុមការងារអង្គភាពនីតិកម្ម និងស្នើសុំឱ្យតាមក្រសួងនីមួយៗ កាលណា ធ្វើលិខិតបទដ្ឋានផ្សេងៗត្រូវឆ្លងកាត់អង្គភាពនីតិកម្មផង។

លោក **លីម យូស្ស** ប្រធាននាយកដ្ឋានសិទ្ធិអក្សនិពន្ធ ក្រសួងវិចិត្រសិល្បៈ ចង់ឱ្យការតាក់តែង ច្បាប់មានស្តង់ដាតែមួយ ដោយលោកលើកឡើងថា កន្លងមកខាងក្រសួងបានធ្វើសេចក្តីព្រាងច្បាប់ ទៅក្រុមប្រឹក្សាអ្នកច្បាប់ ហើយជាញឹកញាប់ ក្រុមប្រឹក្សាអ្នកច្បាប់ថា ខុសស្តង់ដា។

លោក **ហ៊ែល ចំរើន** ប្រធាននាយកដ្ឋាន នៃក្រសួងហិរញ្ញវត្ថុ បានលើកឡើងចំពោះមតិ របស់ដៃគូអភិវឌ្ឍន៍ ក៏ដូចមន្ត្រីមុខងារសាធារណរបស់រាជរដ្ឋាភិបាលដែលបានរិះគន់ថា អង្គភាព

នីតិកម្មគ្មានធ្វើការ ឬដំណើរការអ្វីឡើយ ដូច្នេះលោកបានស្នើសុំឱ្យមានសារាចរណ៍ណែនាំរបស់រាជរដ្ឋាភិបាលទៅដល់ក្រសួង-ស្ថាប័នទាំងអស់ ហើយនិងលោកស្នើសុំឱ្យក្រសួងនីមួយៗ កាលណាធ្វើច្បាប់ត្រូវឆ្លងកាត់អង្គភាពនីតិកម្ម ក៏ដូចជាការចូលរួមប្រជុំទាំងអស់គ្នានិយាយរួមគឺ សហការជាមួយអង្គភាពនីតិកម្ម។ ចំពោះការផ្តល់ប្រាក់លាភការបន្ថែមគឺជារឿងសំខាន់មួយដែរ ដើម្បីឱ្យសមស្របទៅតាមតម្លៃការងារ និងជាលើកទឹកចិត្តផងដែរ។

នាយកដ្ឋានរុក្ខាប្រម៉ាញ់ និងនេសាទ បានសំណូមពរឱ្យមានទម្រង់ណាមួយជាផ្លូវការ ដើម្បីឱ្យមានការងាយស្រួល ក្នុងការសរសេរតាក់តែងច្បាប់បានច្បាស់លាស់ និងស្នើសុំឱ្យក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ តម្រូវឱ្យ ក្រសួងមួយមានអង្គភាពនីតិកម្មតែមួយបានហើយ។

ឯកឧត្តមប្រធានអង្គសិក្ខាសាលាបានធ្វើសេចក្តីសង្ខេបជូនចំពោះអង្គសិក្ខាសាលាទាំងមូលថា នេះជាឱកាសមួយ ដ៏សំខាន់ក្នុងការពិភាក្សាផ្ទាល់ចំពោះមុខ ឯកឧត្តមសង្ឃឹមថា ពេលត្រឡប់ទៅវិញគ្រប់ក្រសួង និងស្ថាប័នទាំងអស់ នឹងផ្ញើនូវមតិយោបល់ផ្សេងៗបន្ថែមមកដល់ក្រុមការងារយើង ដើម្បីរៀបចំជារបាយការណ៍ឱ្យបានគ្រប់ជ្រុងជ្រោយ និងផ្ញើជូនទៅវិញ ដើម្បីជួយកែនូវអនុសាសន៍ម្តងទៀត មុននិងសម្រេចបោះពុម្ព។ ជាមួយគ្នានោះដែរ ឯកឧត្តមប្រធានអង្គសិក្ខាសាលាបានធ្វើការបំភ្លឺរាល់សំណួរ និងសំណូមពររបស់អង្គសិក្ខាសាលាថា ៖

- បញ្ហាប្រាក់លាភការបន្ថែម មានលក្ខណៈសំខាន់ សម្រាប់រាល់ដំណើរការការងារ
- ចំពោះការជំរុញឱ្យបានចេញនូវសេចក្តីណែនាំ និងទម្រង់នៃការសរសេរ ដើម្បីក្រសួង-ស្ថាប័ន សរសេរមកកុំឱ្យមានលក្ខណៈខុសឆ្គង ឯកឧត្តមប្រធាននឹងជំរុញឱ្យសំណូមពរខាងលើនេះបានសម្រេចនៅពេលសមស្រប
- ចំពោះការពង្រឹងធនធានមនុស្ស ក៏ដូចជាការទទួលស្គាល់នូវតម្លៃការងារគឺជារឿងសំខាន់ផងដែរ
- ទាក់ទងនឹងការស្វែងរកមូលនិធិដើម្បីឱ្យក្រសួងមានដំណើរការ លុះត្រាតែធ្វើផែនការសកម្មភាព និងធ្វើផែនការយុទ្ធសាស្រ្ត ទើបដៃគូអភិវឌ្ឍន៍អាចជួយជាថវិកាបាន
- ទាក់ទងនឹងការបណ្តុះបណ្តាលដូចជារបៀបសរសេរ អាចខាងដៃគូអភិវឌ្ឍន៍ជាអ្នកជួយ
- ពាក់ព័ន្ធនឹង PMG &MBPI បើសិនជាដៃគូអភិវឌ្ឍន៍យល់ព្រម ខាងកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ នឹងដាក់ចូលទៅក្នុងគម្រោងកំណែទម្រង់ច្បាប់ និងតុលាការ
- ចំពោះការលើកតម្កើងអង្គភាពនីតិកម្មនោះវាពាក់ព័ន្ធទៅនឹងថ្នាក់ដឹកនាំរបស់ក្រសួង
- ចំពោះស្តង់ដា លុះត្រាតែសេចក្តីណែនាំស្តីពីការតាក់តែងច្បាប់ និងបញ្ជាក់អំពីបញ្ហានេះ។

ជាបញ្ចប់ឯកឧត្តមប្រធានបានថ្លែងអំណរគុណដល់អង្គសិក្ខាសាលាទាំងមូល ដែលបានបញ្ចេញនូវមតិយោបល់យ៉ាងផុសផុល និងបានចំណាយពេលវេលាដ៏មានតម្លៃមកចូលរួមនាថ្ងៃនោះ។

អង្គប្រជុំបានប្រព្រឹត្តទៅដោយរលូន ហើយបានបញ្ចប់នៅម៉ោងដប់ពីរ និងដប់ប្រាំនាទី នាថ្ងៃខែឆ្នាំដដែល។

**បានឃើញ និងឯកភាព**

អគ្គលេខាធិការ

ស៊ុយ ម៉ុងលាង

*រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ ២០០៩*

អ្នកធ្វើកំណត់ហេតុ

ស៊ុន សិរីវុធ